**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ថ្ងៃពុធ ១៤រោច ខែមាឃ ឆ្នាំរកា នព្វស័ក ពស ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៨

**ក្រសួងព័ត៌មាន**
**MINISTRY OF INFORMATION**
លេខ ០៤៥ ព.មសណរ

# សេចក្ដីសម្រេច

## ស្ដីពីការបង្កើតក្រុមការងារជំរុញចលនាភូមិមួយផលិតផលមួយ របស់ក្រសួងព័ត៌មាន

## រដ្ឋមន្ត្រី
## ក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៧/៣៨៣ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលមាត្រា១ និងមាត្រា២ នៃព្រះរាជក្រឹត្យលេខ នស /រកត/ ០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិ ជំរុញចលនាភូមិមួយផលិតផលមួយ
- បានឃើញអនុក្រឹត្យលេខ ១៨៧ អនក្រ.បក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ

## សម្រេច

ប្រការ១.-

ត្រូវបានបង្កើតក្រុមការងារជំរុញចលនាភូមិមួយផលិតផលមួយ នៅក្រសួងព័ត៌មាន។

ប្រការ២.-

ក្រុមការងារនេះមានសមាសភាពដូចខាងក្រោម៖

១.ឯកឧត្តម យឹម វុទ្ធី អគ្គនាយក នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ប្រធាន

២.លោក អ៊ឹម ងួន ប្រធាននាយកដ្ឋានបច្ចេកទេស នៃអគ្គនាយកទូរទស្សន៍ជាតិកម្ពុជា អនុប្រធាន

៣.លោក ម៉ឹង កុសល អនុប្រធាននាយកដ្ឋានព័ត៌មានក្នុងនិងក្រៅប្រទេស នៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា សមាជិក

៤.លោក អ៊ុក សាផាន អនុប្រធាននាយកដ្ឋានព័ត៌មានក្នុងនិងក្រៅប្រទេស នៃអគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា AKP សមាជិក

៥.លោក កុល ផាន់ណា អនុប្រធាននាយកដ្ឋានកិច្ចការបរទេស នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា លេខាធិការ

ប្រការ៣.-

ក្រុមការងារនេះ មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់ខ្លួន ដើម្បីបំពេញភារកិច្ចទៅតាមការចាំបាច់ ។

ប្រការ៤.-

អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា និងសាមីខ្លួនត្រូវអនុវត្តន៍សេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ខៀវ កាញារីទ្ធ

**ចម្លងជូន:**

-ថ្នាក់ដឹកនាំក្រសួងព័ត៌មាន« ដើម្បីជ្រាប »

-ដូចប្រការ២ និងប្រការ៤ « ដើម្បីអនុវត្ត »

-ឯកសារកាលប្បវត្តិ